## សំណួរ និងចម្លើយ ពាក់ព័ន្ធនឹងច្បាប់

### សំណួរ៖ តើអ្វីទៅជាក្របខ័ណ្ឌច្បាប់ និងនីតិវិធីនៃការដាក់ប្រទេសកម្ពុជាក្នុងស្ថានភាពអាសន្ន?

១. មាត្រា ២២ ថ្មី ជាក្របខ័ណ្ឌច្បាប់ សម្រាប់ប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន។ ព្រះមហាក្សត្រទ្រង់ជាអ្នកប្រកាសនូវស្ថានភាពនេះជាសាធារណៈ។ សភា ត្រូវបានតម្រូវឲ្យប្រជុំរាល់ថ្ងៃ ដើម្បីពិនិត្យមើលស្ថានភាពនេះ និងសម្រេចបញ្ចប់។ ទោះបីជាយ៉ាងនេះក្តី ប្រសិនបើសភា មិនអាចប្រជុំ ដោយសារវត្តមាននៃកងកម្លាំងបរទេសចូលមកកាន់កាប់ ការប្រកាសស្ថានភាព នៅបន្តជាស្វ័យប្រវត្តិ (មាត្រា ៨៦)។ ខ្លឹមសារក្នុងមាត្រា ៨៦ នេះ អនុវត្តដូចគ្នាចំពោះស្ថាប័នព្រឹទ្ធសភា (មាត្រា ១០២ថ្មី)។ ក្នុងស្ថានភាពនេះ ទាំងសភា និងព្រឹទ្ធិសភា មិនត្រូវបានរំលាយទេ (មាត្រា ៨៦ និង ១០២ថ្មី)។ បន្ថែមពីលើនេះ «ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឱ្យធ្វើទៅពេលប្រទេសជាតិឋិតក្នុងភាពអាសន្នដូចមានចែងក្នុងមាត្រា ៨៦» (មាត្រា ១៥២ថ្មី)។

២. តាមទ្រឹស្តី ច្បាប់រដ្ឋធម្មនុញ្ញជាច្បាប់កំពូល និងមិនអាចចែងលម្អិតច្បាប់គ្រប់ចំណុចបានទេ។ អាស្រ័យហេតុនេះ ផ្អែកតាមមាត្រា ២២ ថ្មីនៃច្បាប់រដ្ឋធម្មនុញ្ញ រាជរដ្ឋាភិបាល បានអនុម័តច្បាប់ ស្តីពីការដាក់ប្រទេសក្នុងភាពអាសន្ន http://www.measboralaws.com/detail/1086 ដែលមានចែងអំពីនីតិវិធី និងលក្ខខ័ណ្ឌ ក្នុងនោះមានចែងនូវវិធានការដែលនឹងត្រូវបានអនុវត្ត និងទោសទណ្ឌចំពោះបុគ្គល បំពានច្បាប់នេះផងដែរ។

៣. ច្បាប់នេះ បានចែងនូវចំណុចវិជ្ជមានមួយចំនួន ដូចជាការដាក់ទោសទណ្ឌដល់មន្ត្រីដែល ប្រើប្រាស់អំណាចតាមទំនើងចិត្ត ប៉ះពាល់ដល់រូបរាងកាយឬទ្រព្យសម្បត្តិបុគ្គល (មាត្រា ១០) ។ ទោះបីជាយ៉ាងណាក្តីច្បាប់មិនបានចែងចំណុចមួយចំនួន តម្រូវដោយ កតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋនិងនយោបាយឆ្នាំ ១៩៧៧ ដែលកម្ពុជាជាភាគី និងមានចែងយោងក្នុងមាត្រា ៣១ នៃច្បាប់ធម្មនុញ្ញឆ្នាំ ១៩៩៣ ទេ។ អាស្រ័យហេតុនេះ ដើម្បីបញ្ចៀសនូវការបំពានកាតព្វកិច្ចអន្តរជាតិ ការអនុវត្តនូវវិធានការ ឬការបកស្រាយគួរត្រូវបានអនុលោម និងធ្វើតាមតម្រូវរបស់កតិកាសញ្ញានេះ។

<u>មាត្រា ២២ថ្មី.- នៃច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣</u>៖ នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា។